**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១១៦ អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពី**

**ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ**

**របស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២៣៤អនក្រ.បក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់ពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មកាពយន្ត សម្រាប់ប្រើប្រាស់បំពេញការងារ ចុះអនុវត្តច្បាប់ អនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មកាពយន្ត និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធវិស័យកាពយន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

**ជំពូកទី២**

**ឯកសណ្ឋាន**

**មាត្រា២ .-**

ឯកសណ្ឋានរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មកាពយន្ត ត្រូវបានកំណត់ដូចខាងក្រោម៖

**ក- ចំពោះបុរស**

១- អាវ មាន២(ពីរ)ប្រភេទ៖

- អាវដៃខ្លី
- អាវដៃវែង

**១.១- អាវដៃខ្លី**

អាវដៃខ្លីផលិតពីសាច់ក្រណាត់ពណ៌ឈាមជ្រូក កាត់ជាទម្រង់អាវធម្មតាដៃខ្លី កឱប មានហោប៉ៅចំនួន២នៅខាងលើដេរជាលក្ខណៈប៉ះបត់ជាពីរផ្នត់ឆ្វេងស្តាំ គម្របស្លឹកពោធិ៍ ដាក់ឡេវពណ៌ដូចអាវ(រូបភាពទី១ក្នុងឧបសម្ព័ន្ធទី១)។ ឯកសណ្ឋាននេះប្រើប្រាស់សម្រាប់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មកាពយន្តបំពេញការងារប្រចាំថ្ងៃ ពិធីបុណ្យជាតិ សន្និបាត សវនាការ និងករណីតម្រូវក្នុងកម្មវិធីនីមួយៗ។

**១.២- អាវដៃវែង**

អាវដៃវែងផលិតពីសាច់ក្រណាត់ពណ៌ឈាមជ្រូក កាត់ជាទម្រង់អាវធម្មតាដៃវែង កឱប មានហោប៉ៅចំនួន២នៅខាងលើដេរជាលក្ខណៈប៉ះបត់ជាពីរផ្នត់ឆ្វេងស្តាំ គម្របស្លឹកពោធិ៍ ដាក់ឡេវពណ៌ដូចអាវ(រូបភាពទី២ក្នុងឧបសម្ព័ន្ធទី១)។ ឯកសណ្ឋាននេះប្រើប្រាស់ សម្រាប់មន្ត្រី ត្រួតពិនិត្យឧស្សាហកម្មកាពយន្តបំពេញការងារប្រចាំថ្ងៃ ពិធីបុណ្យជាតិ សន្និបាត សវនាការ និងករណីតម្រូវក្នុងកម្មវិធីនីមួយៗ។

២- ខោជើងវែង

ខោជើងវែងផលិតពីសាច់ក្រណាត់ពណ៌ទឹកប៊ិចចាស់ ចង្កេះត ដេរថ្នេរបង្កប់ជីបភ្លីខាងមុខពីរ មានហោប៉ៅបី ហោប៉ៅចំហៀងទាំងសងខាងដេរបញ្ឆិតតាមថ្នេរ ចំហៀងខោ និងហោប៉ៅក្រោយ ដេរថ្នេរបង្កប់នៅខាងស្តាំ និងមានឡេវមួយបង្កប់(រូបភាពទី៣ ឧបសម្ព័ន្ធទី១)។

៣- ស្បែកជើង

ស្បែកជើងឃ្លុបធ្វើពីស្បែកពណ៌ខ្មៅ កខ្លី មានចងខ្សែ មានកែងទាបកម្ពស់៣០មីលីម៉ែត្រ និងមានស្រោមជើងពណ៌ខ្មៅ(រូបភាពទី៤ ឧបសម្ព័ន្ធទី១)។

៤- ខ្សែក្រវ៉ាត់

ខ្សែក្រវ៉ាត់ផលិតពីស្បែក ពណ៌ខ្មៅ មានក្បាលពណ៌ទឹកប្រាក់(រូបភាពទី៥ ឧបសម្ព័ន្ធទី១)។

**ខ- ចំពោះស្ត្រី**

១- អាវមាន២(ពីរ)ប្រភេទ៖

- អាវដៃខ្លី ដូចបុរស តែមានជីបរាង(រូបភាពទី៦ ឧបសម្ព័ន្ធទី១)
- អាវដៃវែង ដូចបុរស តែមានជីបរាង(រូបភាពទី៧ ឧបសម្ព័ន្ធទី១)

២. ខោ

មានលក្ខណៈដូចជាខោបុរសពណ៌ទឹកប៊ិចចាស់(រូបភាពទី៨ ឧបសម្ព័ន្ធទី១)

៣. សំពត់

មានពណ៌ទឹកប៊ិចចាស់ កាត់សំពត់រាងតចង្អេះសម្រុងចុះក្រោមដល់ពាក់កណ្ដាលស្មងជើង ផែកខាងក្រោយមានរូតនៅចំហៀង(រូបភាពទី៩ ឧបសម្ព័ន្ធទី១)

៤. ស្បែកជើង

ស្បែកជើងឃ្លុប ធ្វើពីស្បែកពណ៌ខ្មៅ គ្មានចងខ្សែ កខ្លី ឃ្លុបមុខក្រោយមានកែងទាបកម្ពស់កែង៣០មីល្លីម៉ែត្រ(រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

៥. ខ្សែក្រវ៉ាត់

មានលក្ខណៈដូចខ្សែក្រវ៉ាត់បុរស(រូបភាពទី៥ ឧបសម្ព័ន្ធទី១)។

## ជំពូកទី៣
## សញ្ញាសម្គាល់

**មាត្រា៣ .-**

សញ្ញាសម្គាល់របស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត ត្រូវបានកំណត់ដូចខាងក្រោម៖

១- ស្លាកសញ្ញាសម្គាល់រូបសញ្ញាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវប៉ាក់លើសាច់ក្រណាត់រាងមូលដែលមានទំហំអង្កត់ផ្ចិត៧សង្ទីម៉ែត្រ ដោយដេរភ្ជាប់ពីលើដើមដៃអាវខាងស្ដាំ(រូបភាពទី១១ ឧបសម្ព័ន្ធទី២)។

២- សញ្ញាសម្គាល់និមិត្តសញ្ញាជាអក្សរ **ត្រួតពិនិត្យឧស្សាហកម្មភាពយន្ត** ជាប៉ាក់សម្រាប់ដេរប៉ះលើដៃអាវខាងឆ្វេងមានប្រវែង៥០មិល្លីម៉ែត្រពីថ្នេរស្មាអាវ ក្រណាត់ប៉ាក់កម្ពស់២២មិល្លីម៉ែត្រ និងមានទទឹង១០៥មិល្លីម៉ែត្រ(រូបភាពទី១២ ឧបសម្ព័ន្ធទី២)។

៣- ស្លាកសញ្ញាសម្គាល់សម្រាប់ខ្ទាស់លើហោប៉ៅអាវខាងស្ដាំមានរាងមូលប៉ោង ទំហំ៥៥មិល្លីម៉ែត្រ ធ្វើពីលោហធាតុ ភ្ជាប់ដោយបន្ទះស្បែកមានទម្រង់ជានិមិត្តសញ្ញាអក្សរ **ត្រួតពិនិត្យឧស្សាហកម្មភាពយន្ត** នៅផ្នែកខាងលើ នៅចំកណ្ដាលមានស្លាកសញ្ញាសម្គាល់រូបសញ្ញា នាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌ និងផ្នែកខាងក្រោមមានអក្សរ FILM INDUSTRY CONTROL (រូបភាពទី១៣ ឧបសម្ព័ន្ធទី២)។

៤- ផ្លាកសញ្ញាសម្គាល់ឈ្មោះសម្រាប់ **មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

ផ្លាកសញ្ញាឈ្មោះមន្ត្រី សម្រាប់ពាក់នៅពីលើហោប៉ៅអាវខាងស្ដាំមានរាងចតុកោណកែង ដែលមានបណ្ដោយ៨០មិល្លីម៉ែត្រ ទទឹង២៥មិល្លីម៉ែត្រដែលសរសេរអក្សរពណ៌មាស និង៣សដោយជ័រវែងថ្លាមានផ្ទៃពណ៌ខៀវចាស់ និងមានខ្សែបន្ទាត់ស្តែងពណ៌មាសព័ទ្ធជុំវិញដែលមានទំហំ០,១៥មិល្លីម៉ែត្រ មានសរសេរគោត្តនាម និងនាមជាអក្សរខ្មែរ អក្សរឡាតាំង និងលេខសម្គាល់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត (រូបភាពទី១៤ ឧបសម្ព័ន្ធទី២)។

## ជំពូកទី៤
## សញ្ញាសក្តិ

**មាត្រា៤ .-**

សញ្ញាសក្តិត្រូវបានរៀបចំជា៥(ប្រាំ)ថ្នាក់ប្រើបានទាំងបុរសនិងស្ត្រី(រូបភាពទី៤ ឧបសម្ព័ន្ធទី១)

១. ថ្នាក់ប្រធាននាយកដ្ឋាន

មួកកន្លឹបធ្វើពីសាច់ក្រណាត់ពណ៌ខ្មៅ ផ្នែកខាងមុខមានភ្ជាប់ស្លាកសញ្ញាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានទំហំអង្កត់ផ្ចិត៥៥មិល្លីម៉ែត្រ( ខ្នាតមួកកន្លឹបខាងលើ )។ ផ្នែកខាងក្រោមស្លាកសញ្ញាមានប៉ាក់កម្រងក្បាច់ខ្សែសយពណ៌មាស នៅខាងចុងសងខាងនៃខ្សែសយនេះ មានភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ភ្ញីទេសឱនពណ៌មាស ទម្រង់ស្លែងក្របីដល់ជើងមួក។

**២. ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត**

មួកកន្លឹបធ្វើពីសាច់ក្រណាត់ពណ៌ខ្មៅ ផ្នែកខាងមុខមានភ្ជាប់ស្លាកសញ្ញាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានទំហំអង្កត់ផ្ចិត៥៥មិល្លីម៉ែត្រ( ខ្នាតមួកកន្លឹបខាងលើ )។ នៅលើក្បាំងមួកមានប៉ាក់ភ្ញីទេសឱនពណ៌ទឹកមាស ទម្រង់ស្នែងក្របីដល់ជើងមួក។

**៣. ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត**

មួកកន្លឹបធ្វើពីសាច់ក្រណាត់ពណ៌ខ្មៅ ផ្នែកខាងមុខមានភ្ជាប់ស្លាកសញ្ញាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានទំហំអង្កត់ផ្ចិត៥៥មិល្លីម៉ែត្រ( ខ្នាតមួកកន្លឹបខាងលើ )។ នៅលើក្បាំងមួកមានប៉ាក់ភ្ញីទេសឱនពណ៌ទឹកមាស ទម្រង់ស្នែងក្របីដល់ពាក់កណ្តាលជើងមួក។

**៤. ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាលនិងប្រធានការិយាល័យនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត**

មួកកន្លឹបធ្វើពីសាច់ក្រណាត់ពណ៌ខ្មៅ ផ្នែកខាងមុខមានភ្ជាប់ស្លាកសញ្ញាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានទំហំអង្កត់ផ្ចិត៥៥មិល្លីម៉ែត្រ( ខ្នាតមួកកន្លឹបខាងលើ )។ នៅលើក្បាំងមួកមានប៉ាក់ភ្ញីទេសឱនពណ៌ទឹកប្រាក់ ទម្រង់ស្នែងក្របីដល់ពាក់កណ្តាលជើងមួក។

**៥. ថ្នាក់មន្ត្រីនិងអនុប្រធានការិយាល័យនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត**

មួកកន្លឹបធ្វើពីសាច់ក្រណាត់ពណ៌ខ្មៅ ផ្នែកខាងមុខមានភ្ជាប់ស្លាកសញ្ញាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានទំហំអង្កត់ផ្ចិត៥៥មិល្លីម៉ែត្រ( ខ្នាតមួកកន្លឹបខាងលើ ) និងនៅលើក្បាំងមួកគ្មានប៉ាក់ភ្ញីទេសទេ។

## ជំពូកទី៥
## ការប្រើប្រាស់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ

**មាត្រា៥ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ត្រូវបានប្រើប្រាស់ដោយមន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្តដែលបម្រើការនៅនាយកដ្ឋានសិល្បកាពយន្តនិងផ្សព្វផ្សាយវប្បធម៌ និងមន្ត្រីទទួលបន្ទុកភាពយន្តនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត តាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ប្រើប្រាស់សម្រាប់៖

១- បំពេញការងារប្រចាំថ្ងៃក្នុងអង្គភាព។

២- បំពេញបេសកកម្មពង្រឹងការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត និងច្បាប់នានាពាក់ព័ន្ធក្នុងប្រតិបត្តិការ ស្រាវជ្រាវ តាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ និងបង្ក្រាបបទល្មើសក្នុងវិស័យភាពយន្ត។

៣- ចូលរួមពិធីបុណ្យជាតិ ប្រជុំ និង/ឬ សន្និសីទផ្លូវការផ្សេងៗទៀត។

៤- ចូលរួមក្នុងសវនាការតុលាការ។

**មាត្រា៦ .-**

មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្តម្នាក់ៗ ត្រូវទទួលបានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិដូចមានចែងក្នុងអនុក្រឹត្យនេះចំនួន២( ពីរ )សម្រាប់ ដើម្បីប្រើប្រាស់ក្នុងរយៈពេល១( មួយ )ឆ្នាំ តាមទំហំនៃថវិកាជាតិប្រចាំឆ្នាំដែលបានកែាជជូន។

**មាត្រា៧ .-**

ក្នុងពេលបំពេញបេសកកម្មមន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្តត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ និងមានបណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ ព្រមទាំងលិខិតបញ្ជាបេសកកម្ម។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា៨ .-**

ជនណាដែលបានក្លែងឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ ឬក្លែងបន្លំខ្លួនដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ ឬសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**ភឿង សកុណា**

**<u>កន្លែងទទួល</u>** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# រូបភាពទី១ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧

ស្ដីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

អាវដៃខ្លីបុរស



មើលពីខាងមុខ មើលពីខាងក្រោយ

## រូបភាពទី២ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

អាវដៃវែងបុរស



មើលពីខាងមុខ



មើលពីខាងក្រោយ

# រូបភាពទី៣ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

**ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

**ខោជើងវែងបុរស**



មើលខាងពីមុខ



មើលពីខាងក្រោយ

# រូបភាពទី៤ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧

**ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

ស្បែកជើងនិងស្រោមជើងបុរស



ស្បែកជើង



ស្រោមជើង

# រូបភាពទី៥ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧

ស្ដីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

ខ្សែក្រវ៉ាត់បុរសនិងស្ត្រី



## រូបភាពទី៦ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ.១១៦.អនក្រ.បក.ចុះថ្ងៃទី..២៥...ខែ.កក្កដា....ឆ្នាំ២០១៧

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

អាវដៃខ្លីស្ត្រី



មើលពីខាងមុខ



មើលពីខាងក្រោយ

# រូបភាពទី៧ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក. ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

**ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

**អាវដៃវែងស្ត្រី**



មើលពីខាងមុខ មើលពីខាងក្រោយ

# រូបភាពទី៨ ឧបសម្ព័ន្ធទី១

## នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

## ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត ខោជើងវែងស្ត្រី



មើលខាងពីមុខ



មើលពីខាងក្រោយ

# រូបភាពទី៩ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

**ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

**សំពត់បំពង់ស្ត្រី**



មើលខាងពីមុខ　　　　មើលពីខាងក្រោយ



# រូបភាពទី១០ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

**ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

**ស្បែកជើងកែងចោតស្ត្រី**





## រូបភាពទី១១ ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧
ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត
សញ្ញាសម្គាល់ លើដៃអាវខាងស្តាំ



## រូបភាពទី១២ ឧបសម្ព័ន្ធទី២

**នៃអនុក្រឹត្យលេខ១១៦អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧**

**ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

**សញ្ញាសម្គាល់ លើដៃអាវខាងឆ្វេង**



## រូបភាពទី១៣ ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ...១១៦អនក្រ.បក...ចុះថ្ងៃទី...២៥...ខែ...កក្កដា.....ឆ្នាំ២០១៧

**ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

ស្លាកសញ្ញា មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត



# រូបភាពទី១៤ ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ១១៦អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

**ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

**ស្លាកឈ្មោះ មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**



# រូបភាពទី១៥ ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ១១៦អនក្រ.បក.ចុះថ្ងៃទី..២៥..ខែ.កក្កដា....ឆ្នាំ២០១៧

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

## សញ្ញាសក្តិ មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត



ថ្នាក់ប្រធាននាយកដ្ឋាន



ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត



ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត



ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាលនិងប្រធានការិយាល័យនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត



ថ្នាក់មន្ត្រីនិងអនុប្រធានការិយាល័យនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត